## ព្រះរាជក្រឹត្យ នស/រកត/១១០០/២១២

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់អនុក្រឹត្យលេខ១៤ អនក្រ ចុះថ្ងៃទី៣០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការ រៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងឯកឧត្តម គែម ថន ជាអនុរដ្ឋលេខាធិការ នៃក្រសួងសាធារណការនិងដឹកជញ្ជូន ។

មាត្រា ២ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/១១០០/២១៣

### ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

**ត្រាស់បង្គាប់**

**មាត្រា ១ .-**

ត្រូវបានបញ្ចូលសមាសភាពចំនួនពីរថ្មីទៀត ជាសមាជិកនៃឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋគឺ :

១-ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍ សង្គមកិច្ច

២-ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

**មាត្រា ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-**

នាយករដ្ឋមន្ត្រី ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ .-**

ព្រះរាជក្រឹត្យនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីបង្គំទូលថ្វាយ
ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
**ហ៊ុន សែន**

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
ជ.ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
សមាជិកអចិន្ត្រៃយ៍
ហត្ថលេខា
សុខ អាន